**BBI0085**

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយឈ្មោះ ស សឹង ភេទស្រី អាយុ៥៧ឆ្នាំ

## មុខសារជនខ្មែរក្រហម«ពេទ្យ»

## រស់នៅភូមិកណ្ដាល ឃុំអូររំដួល ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។

## ថ្ងៃទី២០ខែមិនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

## ០០:៥០:៥៨

## ២៦ទំព័រ

វណ្ណៈ: ចឹងខ្ញុំប្រាប់ឈ្មោះទៅមីងថា ខ្ញុំមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាណាមីង?

សឹង: ចាស ។

វណ្ណៈ: ចឹងបទសម្ភាសខ្ញុំជាមីងហ្នឹង តើមីងអនុញ្ញាតឲ្យជំនាន់ក្រោយបានដឹងបានឮពីប្រវត្តិសាស្ត្ររបស់ខ្មែរយើងដែលអត់?

សឹង: ចឹងឲ្យដឹង ។

វណ្ណៈ: ចឹងមីងអនុញ្ញាតមីងណាស់?

សឹង: ចាស ។

វណ្ណៈ: ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង?

សឹង: ស សឹង ។

វណ្ណៈ: ចឹងមីងអាយុ៥៧មែនទេ?

សឹង: ចាស ។

វណ្ណៈ: ឪពុកមីងឈ្មោះអីដែរ?

សឹង: ឪពុកខ្ញុំឈ្មោះ ស៊ុម ។

វណ្ណៈ: ត្រកូលគាត់?

សឹង: ស ស៊ុម ។

វណ្ណៈ: ចឹងម្ដាយ?

សឹង: ម្ដាយឈ្មោះ ប្រុក នួន ។

វណ្ណៈ: ចឹងសព្វថ្ងៃគាត់នៅរស់ដែលអត់ទេ?

សឺន:	នៅម្តាយ ។

វណ្ណៈ:	ចឹងគាត់នៅស្រុកមីង?

សឺន:	ចាស ។

វណ្ណៈ:	ចឹងមីងភូមិកំណើតមីងនៅភូមិអី?

សឺន:	ខ្ញុំនៅភូមិកៅទៃ ។

វណ្ណៈ:	ចឹងឃុំ?

សឺន:	ឃុំមើលចង់ភ្លេចអស់ហើយនេះ ឃុំកោះសំពៅ ។

វណ្ណៈ:	ស្រុក?

សឺន:	ពាមជ ។

វណ្ណៈ:	ខេត្តព្រៃវែង?

សឺន:	ចាស ។

វណ្ណៈ:	ឥឡូវមីងនៅភូមិអី?

សឺន:	នៅភូមិកណ្តាល ។

វណ្ណៈ:	ឃុំ?

សឺន:	ឃុំអូររំដួល ។

វណ្ណៈ:	ស្រុកភ្នំព្រឹក?

សឺន:	ចាស ។

វណ្ណៈ:	ខេត្តបាត់ដំបង?

សឺន:	ចាស ។

វណ្ណៈ:	បងប្អូនមីងមានប៉ុន្មាននាក់?

សឺន:	បងប្អូនមាន១១នាក់តែស្លាប់អស់ហើយ ស្លាប់អស់២ ។

វណ្ណៈ:	ចឹងស្លាប់អស់ប៉ុន្មាននៅសល់ប៉ុន្មាន?

សឺន:	ស្លាប់អស់ពីរហើយ ។

វណ្ណៈ:	ចឹងនៅសល់៩នាក់?

សឺន:	ចាស ។

វណ្ណៈ:	ស្រីប៉ុន្មានប្រុសប៉ុន្មាន?

សឺន:	ស្រី៧ ប្រុស៤ ។

វណ្ណៈ   ចឹងពីរនាក់ហ្នឹងគាត់ស្លាប់ដោយសារអីមានដឹងទេ?

សឹង:   ស្លាប់កាលសម័យឃ្លួនចូលហ្នឹងគេដាក់ថ្នាំរាគ ។

វណ្ណៈ   ចឹងម៉េចដឹងថាដាក់ថ្នាំ?

សឹង:   ចុះខ្ញុំទៅលេងស្រុក ។

វណ្ណៈ   អរ ។

សឹង:   គេមានព្យាបាលណាគេចាក់ថ្នាំឲ្យទៅបណ្តោយ ។

វណ្ណៈ   ចឹងគាត់ជាប្រជាជន គាត់នៅប្រជាជន?

សឹង:   កាលហ្នឹងគាត់ធ្វើទ័ពដែលហ្នឹង ។

វណ្ណៈ   ធ្វើទ័ព?

សឹង:   ចាស!បងគេបង្អស់ ។

វណ្ណៈ   ចុះម្នាក់ទៀត?

សឹង:   បងស្រីទើបស្លាប់ ។

វណ្ណៈ   ស្លាប់ក្រោយ៧៩ទេ?

សឹង:   ទើបស្លាប់ឥឡូវៗដែរពីរឆ្នាំនេះ ។

វណ្ណៈ   គាត់ឈឺ?

សឹង:   ចាស ។

វណ្ណៈ   ចឹងកាលហ្នឹងមីងមានបានរៀនសូត្រអីដែរ?

សឹង:   ខ្ញុំមានបានរៀនអី គិតតែកាន់ភ្ជួរចុះបងៗចេញអស់ហើយ គិតតែភ្ជួរស្រែហ្នឹង ។

វណ្ណៈ   ចឹងក្រោយមកទៀតមីងមានបានរៀនទេ?

សឹង:   កាលសម័យកសាងនៅភ្នំពេញបានរៀនខ្លះអត់ខ្លះ ដល់មករត់ឃ្លួននិងក្មេចអស់ទៅ ។

វណ្ណៈ   ចឹងឥឡូវអត់មានចេះមើលអក្សរអីទេ?

សឹង:   អត់ ។

វណ្ណៈ   តែបានកូនចេះ?

សឹង:   កូនមិនសូវចេះប៉ុន្មាន ។

វណ្ណៈ   ចឹងមិនសូវបានទៅរៀនដែរ?

សឹង:   ចាស!ព្រោះយើងអត់ ។

វណ្ណៈ	ចឹងកាលហ្នឹងមីងចូលបដិវត្តតាំងពីឆ្នាំណា       តាំងពីរដ្ឋប្រហារហើយឬក្រោយមកទៀតបានមីងចូល?

សីង:	ខ្ញុំចូលមកភ្នំពេញតាំងពី៧៦ ។

វណ្ណៈ	ចឹងកាល៧៥មីងនៅណា?

សីង:	កាល៧៥ នៅសហករណ៍លើកទំនប់លើកអី ។

វណ្ណៈ	ចឹង?

សីង:	ចាស ។

វណ្ណៈ	ចឹងកាល៧៥មីងនៅសហករណ៍លើកទំនប់អីទេ?

សីង:	ចាស ។

វណ្ណៈ	កាល៧៥ហ្នឹងនៅជាមួយឪពុកម្តាយ?

សីង:	នៅជាមួយឪពុកម្តាយចុះបងប្អូនគេចេញអស់ហើយ ។

វណ្ណៈ	ចឹងបងៗមីងទេដែលបានទៅធ្វើទ័ពមុន?

សីង:	ចាស ។

វណ្ណៈ	ចឹងកាល៧៦មកភ្នំពេញហ្នឹង  កាលហ្នឹងពីណាទៅជ្រើសរើស?

សីង:	ប្រធានស្រុក  ពូម៉េងគាត់ទៅរើស ។

វណ្ណៈ	ចឹងប្រធានស្រុក?

សីង:	ចាស ។

វណ្ណៈ	ចឹងកាលមីងមកភ្នំពេញហ្នឹងកាលហ្នឹងគេរើសមកគ្នាច្រើនទេ?

សីង:	គេរើសមកច្រើន ។

វណ្ណៈ	គេរើសប្រហែលជាប៉ុន្មានឡានប៉ុន្មាននាក់ទៅ?

សីង:	កាលហ្នឹងជិះកាណូតមកហ្នឹង ។

វណ្ណៈ	ចឹងជិះកាណូតទេ?

សីង:	ចាស ។

វណ្ណៈ	ជិះកាណូតប្រហែលជាប៉ុន្មាននាក់ដែលកាលហ្នឹង?

សីង:	ប្រហែលជា៥០ ទៅ៦០ នាក់ទាំងស្រីទាំងប្រុសមកដល់បែកគ្នាទាំងអស់គេរើសទៅតាមកន្លែង ។

វណ្ណៈ	ចឹងកាលមុននិងមកហ្នឹងគេមានណែនាំយ៉ាងម៉េចថាឲ្យមកនៅភ្នំពេញធ្វើអីមីងមានដឹងទេ?

សីផៈ	កាលដែលស្រុករើសមកហ្នឹងប្រាប់ថាឲ្យទៅរៀនពេទ្យនៅត្រឹមតំបន់ទេ ក្នុងតំបន់ណាស់ ។

វណ្ណៈ	បាទ ។

សីផៈ	ស្រាប់តែមកដល់តំបន់គេមិនប្រាប់ណា គេដឹកឡានទៅឡើងជិះកាណូតមកកំពង់ចាម ។

វណ្ណៈ	បាទ ។

សីផៈ	ឡើងជិះកាណូតពីហ្នឹងមកវិញ ។

វណ្ណៈ	ចឹងកាលហ្នឹងមីងមានស្គាល់គណៈតំបន់គណៈភូមិភាគហើយនៅ?

សីផៈ	កាលហ្នឹងស្គាល់ខ្លះដែលហ្នឹង ។

វណ្ណៈ	ស្គាល់ពីណាគេ?

សីផៈ	តា ឈូកតាអី ។

វណ្ណៈ	តា ឈូក?

សីផៈ	ចាស ។

វណ្ណៈ	ចឹងតា ឈូកគាត់ជាគណៈតំបន់មែនទេ?

សីផៈ	ចាស ។

វណ្ណៈ	គាត់មានឈ្មោះស្អីឈូក?

សីផៈ	ខ្ញុំអត់ចាំទេ ។

វណ្ណៈ	ចឹងគណៈភូមិភាគដូចជាសោភឹមអីមីងស្គាល់ទេ?

សីផៈ	ខ្ញុំភ្លេចអស់ហើយពូអើយ ។

វណ្ណៈ	ចឹងមីងរៀបរាប់មើលមីងមកដល់ភ្នំពេញមីងទៅធ្វើរោងចក្រខាងអី?

សីផៈ	មើលមកដល់មុខវាំងមុនដំបូងគេមិនទាន់ឲ្យធ្វើអីទេ គេឲ្យយើងដើរបោសស្អាតតាមផ្ទះថ្មណាពូកាលហ្នឹង ។

វណ្ណៈ	បាទ ។

សីផៈ	យើងបោសស្អាតហើយគេដាំបាយឲ្យយើងហូប ខ្លះហូបហើយក៏យំទៅចុះបាយក្រអូបអីក្រអូបព្រោះទើបរំដោះហើយភ្លាមៗនោះ ។

វណ្ណៈ	បាទ ។

សីផៈ	ដល់ហើយបានគេរើសទៅតាមរោងចក្រ ។

វណ្ណៈ	មីងនិយាយទៅទៀតទៅ?

សីផៈ	ខ្ញុំនៅរោងចក្រនិងមុនដំបូងនៅកន្លែងបើកបរ ដឹកដីដឹកអី ។

វណ្ណៈ	មីងនៅបើកបរគេឲ្យមីងធ្វើអីបើមីងស្រី បើកបរដែលឬយ៉ាងម៉េច?

សីង:	ទេ នៅដាំបាយឲ្យប្រុសៗអ្នកធ្វើការហ្នឹងហូបណាស់ នៅដាំបាយដាំទឹកហ្នឹងដល់ចេញពីហ្នឹងទៅខ្ញុំទៅនៅកន្លែងពេទ្យ ។

វណ្ណៈ	ចឹងមីងមានចាំទេមីងធ្វើពេទ្យនៅឆ្នាំណា?

សីង:	មិនបានចាំទេ ។

វណ្ណៈ	ពេទ្យនិងពេទ្យណាពេទ្យ៦មករាឬពេទ្យណា?

សីង:	អត់ទេ ពេទ្យដូចថានៅតាមកន្លែងចឹង តាមរោងចក្រមានកន្លែងគេមួយចឹងទៅគេធ្វើពេទ្យមួយចឹងដើម្បីព្យាបាលអ្នកជំងឺតាមរោងចក្រ ។

វណ្ណៈ	ពេទ្យនៅអន្លក់ភាពណា ពេទ្យអន្លក់ភាពរោងចក្រណាទៅរោងចក្រតម្បាញ់ឬរោងចក្រស្អី?

សីង:	អត់ទេ កន្លែងខ្ញុំនៅរោងចក្រក្រឡឹងហើយខ្លះគេនៅកន្លែងចិញ្ចឹមសត្វ គេនៅកន្លែងពេទ្យចឹងទៅ ខ្លះនៅកន្លែងរោងចក្រកន្លែងធ្វើស្រែធ្វើអី នៅកន្លែងពោធិចិនតុង ។

វណ្ណៈ	ចឹងកាលហ្នឹងការហូបចុកអីធម្មតាមិនលំបាកទេ?

សីង:	អត់លំបាកទេ ធម្មតា ។

វណ្ណៈ	ចឹងកាលហ្នឹងមានគេដើរធ្វើប្រវត្តិរូបអីទេ?

សីង:	រឿងប្រវត្តិរូបនោះធ្វើសារចុះសារឡើងវិលមុខហើយគេតាមដានប្រវត្តិរូបនោះ ។

វណ្ណៈ	ចឹងមានការធ្វើប្រវត្តិរូបជាច្រើនដង?

សីង:	ញឹកណាស់ បើថាប្រជុំមួយថ្ងៃម្ដងៗ តាមក្រុមតាមផ្នែកគេ ពួកគេ៣នាក់៥នាក់ ។

វណ្ណៈ	បាទ ។

សីង:	ប្រជុំរាល់តែថ្ងៃ ។

វណ្ណៈ	បាទ!ចឹងនៅកន្លែងរោងចក្រក្រឡឹងអីហ្នឹងប្រធានរោងចក្រមីងមានស្គាល់ទេ?

សីង:	ខ្ញុំមិនសូវស្គាល់ទេ ខ្ញុំនៅកន្លែងពេទ្យវាដាច់ឆ្ងាយពីគ្នា ។

វណ្ណៈ	ចឹងនៅកន្លែងពេទ្យពីណាជាប្រធានពេទ្យ?

សីង:	មីងភឿនគាត់ខាងពេទ្យតែគេវៃចោលអស់ហើយ ។

វណ្ណៈ	ចឹងគាត់ឈ្មោះមីងភឿន?

សីង:	ចាស ។

វណ្ណៈ	គាត់នៅខាងណាបានគេវៃចោលគាត់ខាងបូព៌ាដែលឬខាងណា?

សីង:	គាត់ខាងបូព៌ាប្ដីគាត់ក៏នៅបូព៌ា ។

វណ្ណៈ	ចឹងប្ដីគាត់គេវ៉ៃចោលដែរ?

សឹង:	ចាស ។

វណ្ណៈ	ខាងណាគេយកវ៉ៃចោលខាងនិរតីចាប់គាត់?

សឹង:	ខ្ញុំមិនដឹងដែរ ខ្ញុំមិនសួរដឹង ចុះគាត់ដើរធ្វើការបាត់ៗគាត់មានដែលនៅកន្លែងណាជាមួយពួកយើងណា ដល់មានអ្នកជំងឺធ្ងន់ដូនទៅភ្នំពេញបណ្ដោយ ។

វណ្ណៈ	ចឹងពេទ្យដូចមីងនេះព្យាបាលតែអ្នកឈឺធម្មតាទេ អត់មានព្យាបាលអ្នករបួសមកតាមព្រំដែនអីទេ?

សឹង:	អត់មានទេ កាលហ្នឹងអត់មានទេ ។

វណ្ណៈ	ចឹងកន្លែងធ្វើការហ្នឹងមានដែលឃើញអ៊ឹ ប៉ុល ពត អ៊ឹ អៀង សារីគាត់ទៅលេងដែលទេ?

សឹង:	អត់ដែលមានទេ ចុះពេទ្យវាតូចដែរ តែមានគេមកពីទិវ៉ាលមានគ្រុនចាញ់អីចឹងណាស់ បើយើងដឹកទៅឆ្ងាយមិនទាន់យើងព្យាបាលនៅហ្នឹងសិន បើធ្ងន់បានយើងបញ្ជូនទៅទៀត ។

វណ្ណៈ	ចឹងមីងធ្វើពេទ្យចឹង មីងគេមានឲ្យទៅទស្សនាឬទៅមើលបទពិសោធន៍នៅពេទ្យផ្សេងៗដូចជានៅពេទ្យ៧មករា ពេទ្យរុស្សីជាមួយតា ជួន ជឿនអី?

សឹង:	អត់ទេ ហ្នឹងទៅតែប្រធានគេបណ្ដោយ ។

វណ្ណៈ	ចឹងមីងមិនដែលបានទៅទេ?

សឹង:	មិនដែលបានទៅទេ ។

វណ្ណៈ	ចឹងពេទ្យកន្លែងមីងហ្នឹងមានគ្នាប៉ុន្មាននាក់?

សឹង:	មាន៣ទៅ៤នាក់មានគ្នាតិចដែលហ្នឹងពេទ្យតូច ។

វណ្ណៈ	ចឹងមីងគ្រាន់តែជាអ្នកឲ្យថ្នាំគេលេបឬជាអ្នកចាក់ថ្នាំគេដែរ?

សឹង:	កាលហ្នឹងមានថ្នាំអីលេបមានតែឲ្យថ្នាំគ្រាប់ មិនមានថ្នាំអីវិសេសវិសាលផងមានថ្នាំអីចាក់ផងមានតែថ្នាំគ្រាប់លេបនិងថ្នាំទឹកលេបហ្នឹង ។

វណ្ណៈ	បាទ ។

សឹង:	មានអីសំខាន់ ។

វណ្ណៈ	ចឹងមិនចាំរកអ្នកចេះទេ បើឲ្យថ្នាំតែមួយមុខចឹង?

សឹង:	ចាស!មានតែថ្នាំខ្មៅៗ ។

វណ្ណៈ	ចឹងមីងមានសង្កេតមើលនៅក្នុងអង្គភាពមីងនិងកន្លែងអង្គភាពគេអីហ្នឹង ចឹងកាលហ្នឹងមីងមានសង្កេតឃើញថាមានការបាត់ខ្លួនមានគេចាប់មនុស្សអីមីងមានបានដឹងទេ?

សីផ:	កាលហ្នឹងដូចថាពូងផនិងខ្ញុំចឹងដឹងថាខ្ញុំស្រឡាញ់ពូងផហ្នឹង គេចាប់ប្រុសទៅបាត់គេចាប់ដាក់ឡានជាប់ខ្នោះដៃមិនដឹងជាដឹកយកទៅណាទេ ។

វណ្ណៈ:	ចឹងនៅក្នុងសម័យនិងមានអ្នកលួចស្រឡាញ់គ្នាដែរ?

សីផ:	មានស្រឡាញ់យើងមិនដឹងខ្លួនតែប្រុសគេដឹង គេដឹងថាស្រឡាញ់គេចាប់ទៅបាត់ហើយ ។

វណ្ណៈ:	គ្រាន់ដឹងថាស្រឡាញ់និងមិនទាន់បានប៉ះខ្លួនប្រាណអីផងហ្នឹង?

សីផ:	អត់បានទេ យកទៅហើយ ។

វណ្ណៈ:	ចឹងទំរាំបានប៉ះខ្លួនប្រាណទៀតកាន់តែធ្ងន់ហើយ?

សីផ:	ចាប់ដាក់ខ្នោះទៅរុយៗនោះ ខ្ញុំឃើញដាក់ស្ពែងនិងភ្នែកហើយ ។

វណ្ណៈ:	ចឹងអ្នកដែលគេចាប' ខ្លួននិងមីងមានស្គាល់ឈ្មោះគេដែរ?

សីផ:	ស្គាល់ខ្លះៗមនុស្សក្នុងរោងចក្ររាប់ពាន់នាក់ ។

វណ្ណៈ:	ចឹងអ្នកខុសសីលធ៌?

សីផ:	មានពីណាខុសទេ គ្រាន់ដឹងថាស្រឡាញ់មិនបានផង ។

វណ្ណៈ:	ចឹងឲ្យដឹងថាស្រឡាញ់អីចាប់ដាក់ឡានយកវៃចោលតែម្តង?

សីផ:	ចាប់ដាក់ឡានតែមិនដឹងជាយកទៅខាងណា ។

វណ្ណៈ:	ចឹងមីងកាលហ្នឹងគេមានបញ្ចាំងកុនឲ្យមីងមើលដែលកាលនៅភ្នំពេញហ្នឹង?

សីផ:	មានបញ្ចាំង ។

វណ្ណៈ:	គេបញ្ចាំងកុនរឿងអីខ្លះទៅ?

សីផ:	បញ្ចាំងកាលជំនាន់និងមានតែរឿងចិនជិះកង់ស្អី៨នាក់អី គេឲ្យទៅមើលខ្ញុំមិនសូវទៅមើលព្រោះខ្ញុំខ្លាច ។

វណ្ណៈ:	មីងខ្លាចអីគេ?

សីផ:	អត់ហ៊ានទេ ឲ្យតែរឿងកុនខ្ញុំមិនដែលទៅ ។

វណ្ណៈ:	ចឹងកាលសម័យមីងនិងមានអង្គការចាត់តាំងឲ្យរៀបការអីមានទេ?

សីផ:	កាលហ្នឹងមានឲ្យចាប់ដៃ ។

វណ្ណៈ:	ចឹង?

សីផ:	ដូចថាអ្នកទៅស្រឡាញ់បេះៗ ស្រឡាញ់អត់បានទេ ទៅបានអ្នកផ្សេងវិញ គេឲ្យចាប់ដៃគ្នាខ្ញុំអីគេឲ្យទៅចាប់ដៃដែរ តែខ្ញុំកុហក់អ្នកទៅមុនប្រាប់ហើយខ្ញុំកុហក់ថាឈឺទៅ ។

វណ្ណៈ:	បាទ ។

សីន: ទាល់តែរត់យួនបណ្ដេញ មួយអាទិត្យ១០គូរៗ ។

វណ្ណៈ: បាទ ។

សីន: គេយកឲ្យប្ដេជ្ញាបណ្ដេញ ។

វណ្ណៈ: បាទ ។

សីន: ចុះប្រធាននៅកន្លែងពេទ្យជាមួយគ្នា ចុះគាត់អាយុ២១ហើយប្រពន្ធអាយុ៤០ជាងវ៉ាន់ ។

វណ្ណៈ: យ៉ាងម៉េចចឹង?

សីន: ចឹងហើយគេយកចាប់ដៃនោះ ម្លោះហើយគាត់ប្រាប់ខ្ញុំមិនឲ្យទៅធ្វើល្បិចឈឺរហូតទៅ ។

វណ្ណៈ: ចឹងបើយើងធ្វើល្បិចឈឺចឹងយើងមិនបានទៅរៀបការទេ?

សីន: អត់ទេ មួយអាទិត្យដឹងថា១០គូរគេថាយកយើងទៅរៀនសូត្រ តែយកទៅការឲ្យទេ យកទៅរៀនសូត្រអីយកទៅចាប់ដៃប្ដេជ្ញា ។

វណ្ណៈ: ហើយយើងមិនមានសិទ្ធជ្រើសរើសទេ?

សីន: អត់ទេ យើងស្រឡាញ់គ្នាមិនបានទេ បានគូរផ្សេង មានជាប់គ្នាទេកាលរត់យួននេះខ្លះបែកខ្លះបានគ្នា បានគ្នាភាគតិចដែរ ។

វណ្ណៈ: ចឹងមានយកគ្នាភាគតិចដែរ?

សីន: ចាស ។

វណ្ណៈ: ចឹងកាលហ្នឹងគេរត់ទៅស្រុកកំណើតដោយសាមិនស្រឡាញ់គ្នា ចឹងបើជ្រុលមានកូនហើយយើងបែកគ្នាយ៉ាងម៉េចទៅមីង?

សីន: ពូអើយដូចមួយនៅខ្ញុំនោះ ពេលការហើយចឹងគេឲ្យសម្រាកជុំគ្នាមួយអាទិត្យដល់ម៉ោង១១ទៅកន្លែងវិញ ។

វណ្ណៈ: បាទ ។

សីន: ចុះគេយាមតាមដានតាមផ្ទះ គេថាយើងស្រឡាញ់គ្នាមិនស្រឡាញ់គ្នាវាខុសគូរនោះ ។

វណ្ណៈ: បាទ ។

សីន: វាទៅសម្ងំដេកទៅដល់ម៉ោង១១ ទៅកន្លែងវាវិញទៅមានបានដេកនៅអីទាល់រត់យួនបែកគ្នាតែម្ដង ។

វណ្ណៈ: ចឹងខាងប្រុសគេមិនថាអី?

សីន: អាប្រុសនិងឯងវាមិនព្រមវាមិនស្រឡាញ់ ។

វណ្ណៈ: ចឹងវិញ?

សីផ:　ខាងស្រីមិនអីទេ ។

វណ្ណៈ:　ចឹងខាងប្រុសមិនស្រឡាញ់វិញ?

សីផ:　ចាស ។

វណ្ណៈ:　ហើយខាងស្រីក៏មិនរាយការណ៍ដែរ?

សីផ:　អត់ទេ សម្ងំៗទៅ ។

វណ្ណៈ:　ដេកជិតគ្នារាប់ឆ្នាំ?

សីផ:　ដូចថាផ្ទះមួយពីរខ្នងចឹង មានបន្ទប់បីបន្ទប់ប្អូនខ្ញុំដេកមួយបន្ទប់គេដេកមួយបន្ទប់ ដល់ការហើយគេដេកមួយបន្ទប់ចឹង ដល់ប្រុសឡើងមកស្រីនិងរត់មកបន្ទប់ខ្ញុំទៅ ។

វណ្ណៈ:　ចឹងគេអត់មានតាមដានទេ?

សីផ:　ចុះមានពីណាមានតែពួកខ្ញុំនិងហើយតាមដាន ។

វណ្ណៈ:　ចឹងចេះតែជួយគ្នាទៅ?

សីផ:　ចេះជួយគ្នាទៅ ។

វណ្ណៈ:　បើអត់ស្រឡាញ់?

សីផ:　ចាស!ឥឡូវនៅភូមិដូងស្តាយក្រោយ ស្រីមិនសូវសំខាន់ទេ សំខាន់រឿងប្រុសហ្នឹង ។

វណ្ណៈ:　ម៉េចបានស្តាយក្រោយ ឥឡូវគាត់មានប្តីហើយតើ?

សីផ:　វាបែកខ្ញុំមិនដឹងជាយ៉ាងម៉េចទេ ខាងប្រុសគេទៅស្រុកបាត់ហើយ ។

វណ្ណៈ:　ចឹងអ្នកដែលមកស្រុកភូមិជាមួយមីងមានគ្នាច្រើនទេ?

សីផ:　កាលនោះគេជ្រើសរើសតែមកដល់ភ្នំពេញបែកគ្នាអស់ ។

វណ្ណៈ:　បាទ ។

សីផ:　ដូចថាម៉ាស្រុកខ្ញុំចឹងមកនៅកន្លែងហ្នឹងតែខ្ញុំទេ បែកអស់ហើយមិនបាននៅជុំគ្នាទេ ។

វណ្ណៈ:　ចឹងមីងនៅពេទ្យរហូតដល់៧៩បណ្តោយ?

សីផ:　ខ្ញុំនៅពេទ្យគ្រាន់តែជួយមើលអ្នកជំងឺអីចឹងទៅ បើមិនមានទេមកជួយមើលកន្លែងកុមារអីចឹងណាស់ ។

វណ្ណៈ:　ចឹងមីងនៅពេទ្យចឹងមីងដែលជួបអ្នកស្រីអៀង ធីរិទ្ធគាត់ទៅទេ?

សីផ:　អត់ទេ មិនដែលជួបទេ ។

វណ្ណៈ:　បាទ ។

សីផ:　ព្រោះយើងនៅដាច់ស្រយាលដាប់ផ្លូវរថភ្លើងនេះហើយ ។

វណ្ណៈ នៅពោធិចិនតុងខាងណា?

សឺង: នៅកន្លែងទឹកថ្លានិងហើយ ។

វណ្ណៈ ចឹងនៅទឹកថ្លាហ្នឹង?

សឺង: ចាស ។

វណ្ណៈ ចឹងកាលហ្នឹងមីងមានដើរបានមើលទេសភាពក្នុងភ្នំពេញមានសភាពស្ងាត់ឈឹងឬមួយយ៉ាងម៉េចដែរ?

សឺង: ស្ងាត់ឈឹងហ្នឹងឯងមានអី អត់ផងហ្នឹងមានតែរោងជក្រគេខោអាវក្បែរៗហ្នឹងដើរទៅលេងគ្នាទៅ ។

វណ្ណៈ ចឹងកាលមីងធ្វើការនៅភ្នំពេញហ្នឹងជាមួយពួកចិនៗដែលឬមួយអត់ទេ?

សឺង: អត់ផងហ្នឹង មានធ្វើជាមួយចិនអី ចិនវានៅភ្នាស់ពង់ទា នៅពោធិចិនតុង ។

វណ្ណៈ ចឹងកាលហ្នឹងមីងចេញពីពេទ្យមកនៅពោធិចិនតុងទៀតឬមួយអត់ទេ?

សឺង: អត់ទេ ។

វណ្ណៈ ចឹងមីងម៉េចដឹងថាចិនភ្នាស់ពង់ទា?

សឺង: ចុះចិននៅកន្លែងខ្ញុំ ។

វណ្ណៈ កន្លែងអីគេ កន្លែងពេទ្យហ្នឹងដែរ?

សឺង: កន្លែងចិញ្ចឹមសត្វ ។

វណ្ណៈ ចឹងមីងនៅកន្លែងចិញ្ចឹមសត្វទៀត?

សឺង: អត់ទេ ពេទ្យនិងកន្លែងចិញ្ចឹមសត្វនិងនៅជាប់គ្នាទាំងអស់ ។

វណ្ណៈ អរចឹងទៅ ចឹងចិនៗច្រើនទេ?

សឺង: ចិនមានតែម្នាក់ទេ គាត់ចាស់ ។

វណ្ណៈ ចាស់?

សឺង: សម្រាប់គេយកមកពីកន្លែងណារោងចក្រណាអីចឹង ភ្នាស់ឲ្យគេទៅគេយកទៅចិញ្ចឹម ។

វណ្ណៈ ចឹងចិនជាអ្នកភ្នាស់?

សឺង: ចាស ។

វណ្ណៈ ចិនមកពីស្រុកចិនឬចិននៅស្រុកខ្មែរហ្នឹង?

សឺង: ចិនមិនមែននៅស្រុកខ្មែរយើងទេ ចិនមិនមានប្រពន្ធ កូនទេ ។

វណ្ណៈ ចឹងមីងដែលឃើញគាត់ចេញចូលទៅក្រៅប្រទេសវិញទេ?

សឹងៈ	អត់ គាត់សុំខ្ញុំធ្វើកូនហ្នឹង តែពងទាមួយស៊ីបួនទៅរបាំថ្ងៃមិនអស់ទេ ។

វណ្ណៈៈ	យ៉ាងម៉េចចឹង?

សឹងៈ	វាដាក់តែចង្កឹះលិតបន្តិចទៅបាយអស់ពីរបីចានចង្កឹះហើយ ។

វណ្ណៈៈ	ចឹងចិនហ្នឹង?

សឹងៈ	ចាស!សាច់ជ្រូកអីមួយដុំស៊ីទាល់ចាក់ចោលនោះ មិនមែនហូបដូចយើងទេ ។

វណ្ណៈៈ	ហើយយើងហូបចុកអីធម្មតាទេ កាលនៅកម្មករមីង?

សឹងៈ	មានលំបាកអីអត់ផងហូបបរបូរ ។

វណ្ណៈៈ	យើងនិយាយការពិតបើអត់ពិបាកថាអត់ពិបាកបើពិបាកថាពិបាក?

សឹងៈ	អត់មានពិបាកទេ ។

វណ្ណៈៈ	បាទ!ភាគច្រើនចឹងមែន ចឹងមីងការមីងធ្វើការនៅក្នុងភ្នំពេញពីឆ្នាំ៧៦ដល់៧៩ហ្នឹង មីងមានដែលសុំគេទៅលេងផ្ទះទេ?

សឹងៈ	គេថា៧៩គេឲ្យទៅលេងឪពុកម្ដាយគេត្រៀមកងឡានកង់អីគេកាត់ស្បែកជើងគេឲ្យក្រណាត់កាត់ខោអាវ ចុះកាលយើងរំដោះភ្លាមក្រណាត់ភ្នំពេញមានខ្វះអី ។

វណ្ណៈៈ	បាទ ។

សឹងៈ	ប្រុសៗយកមកឲ្យកាត់ខោអាវទុកផ្ញើម៉ែ ។

វណ្ណៈៈ	បាទ ។

សឹងៈ	ថា៧៩ហ្នឹងទៅ ដល់ហើយមានបានទៅណាយួនចូលមកបណ្ដោយ យួនចូលថាមិនទៅណាប៉ុនដល់ហើយមេៗគេចាប់សែងបោះដាក់ឡានទៅ ។

វណ្ណៈៈ	ពីណាគេ?

សឹងៈ	បងហ៊ិនហ្នឹង ខ្លាចយើងនៅទៅផ្ទះនោះ ។

វណ្ណៈៈ	ចឹងហ៊ិនហ្នឹងគាត់ប្រធានស្អីគេ?

សឹងៈ	ខាងផ្នែករោងចក្រហ្នឹងគាត់នៅកន្លែងចឹញ្ចឹមសត្វដែរ ។

វណ្ណៈៈ	ចឹងកាលហ្នឹងមានស្គាល់តា រិទ្ធប្រធានពាណិជ្ជកម្មអី?

សឹងៈ	អត់ទេ ជំនាន់ហ្នឹងខ្ញុំមិនសូវស្គាល់គេ ។

វណ្ណៈៈ	ចឹងមីងនៅក្នុងសម័យខ្មែរក្រហមបីឆ្នាំ មីងមានដឹងថាមានការសម្លាប់មនុស្សហើយប្រជាជននៅតាមជនបទអីអត់មានអាហារហូបអីមីងមានដឹងទេ?

សឹងៈ	ខ្ញុំអត់បានដឹងផង ។

វណ្ណៈ: ចឹងមីងមិនបានដឹងទេ?

សីង: ចាស ។

វណ្ណៈ: ចឹងកាលហ្នឹងមីងគេមិនឲ្យទៅលេងផ្ទះដែរ?

សីង: អត់!បែកម៉ែឪតាំងពី៧/៦មករហូត ទើបយើងផ្តាច់ខ្លួននិងបានទៅ ។

វណ្ណៈ: ចឹងនៅពេលយួនចូលមកដល់ភ្លាមចឹង មីងនៅខាងខេត្តព្រៃវែងមីងមានបេះយួនអីខ្លះទេ?

សីង: កាលមុនបេះនិងឯងទៅផ្សារទិញឥវ៉ាន់នៅស្រុកយួនហ្នឹង ។

វណ្ណៈ: ចឹងកាលយួនចូលមកមានចិត្តចង់រត់ទៅស្រុកវិញកុំរត់មកតាមគេឯងអត់មានបានគិតចឹងទេ?

សីង: ថាមិនមកទេ ចិនវាធានាថានាំខ្ញុំទៅផ្ទះតើ ។

វណ្ណៈ: បាទ ។

សីង: ថាចាំកុងជូនអាយិនទៅដល់ផ្ទះ មិនបាច់រត់ទេដល់ហើយគេចាបបោះដាក់ឡានបោះខោអាវដាក់វ៉ាលីឲ្យទៅ បានរត់និងគេទៅគេដើររហូតខ្ញុំជិះរហូត កុំគេចាប់ដាក់ឡានមកដល់ផ្ទះតាំងពីយូរនោះ ។

វណ្ណៈ: ចឹងមកជាមួយជនជាតិចិនទៅ?

សីង: អត់ទេ ចិនអត់ចេញផង ។

វណ្ណៈ: ចឹងឲ្យមីងមកវាអត់មកជាមួយ?

សីង: វាអត់មកទេ វានៅហ្នឹងឯងវានៅមើលទាអីហ្នឹងវាមានមកអីវា ចិនមានឲ្យមកណាអោបដៃខ្ញុំយំវាមិនឲ្យមកទេ វាស្រឡាញ់ផ្ញើកូន ។

វណ្ណៈ: ចឹងយ៉ាងម៉េចបានជាមិនរត់បើ៧/៩យួនចូលមកហើយ?

សីង: គេមិនរត់ភាគច្រើនបណ្តោយ អ្នកអត់រត់គេនៅហ្នឹងគេចាប់ផ្ទះបាន ។

វណ្ណៈ: បាទ!ចឹងមីងរត់មកដាយដែនមិនមែនដោយសាថាខ្លាចយួនទេឬក៏ខ្លាចយួនដែរ?

សីង: កាលហ្នឹងមិនដឹងថាយួនអីផង គេចេញឡើងស្វាត់រោងចក្រអស់រលីង ខ្ញុំចេញមកក្រោយគេហ្នឹង ។

វណ្ណៈ: ចឹង?

សីង: គេចេញបានមួយថ្ងៃហើយបានពួកខ្ញុំចេញមកក្រោយគេហ្នឹង ។

វណ្ណៈ: ចឹង?

សីង: ចេញយន្តហោះទម្លាក់ពោធិចិនតុងអីហើយហ្នឹងបានពួកខ្ញុំចេញនោះដែនការមានពីណាចេញ ។

វណ្ណៈ៖ ចឹងនៅពេលមីងចេញមកតាមផ្លូវមីងនិយាយថាជួបគេសម្លាប់អីយ៉ាងម៉េចនៅណាហេតុការណ៍ដែលគេសម្លាប់ហ្នឹង?

សុីង៖ កាលគេសម្លាប់និងខ្ញុំជួបនៅទិវ៉ាល់អីហើយ ។

វណ្ណៈ៖ នៅពេលរត់មកហ្នឹង?

សុីង៖ ចាស ។

វណ្ណៈ៖ ចឹងកាលមីងរត់មកដើរកាត់ព្រៃឬមួយជិះឡានអីមក?

សុីង៖ ខ្ញុំជិះឡានមកមានបានដើរអីជិះឡានរហូតហ្នឹង ។

វណ្ណៈ៖ ចឹងដូចមីងនិយាយមិញហ្នឹងថានៅទិវ៉ាល់ជួបបញ្ហាអីខ្លះ?

សុីង៖ កាលនៅទិវ៉ាល់ហ្នឹងគេយកមនុស្សទៅវៃចោលនៅភ្នំកងវិយកទោសម្លាប់ហើយពួកខ្ញុំគេឲ្យថែមទ័ពប្រាប់ឲ្យយើងយាមទល់ខ្លួនគ្នា ខ្លាចគេអូសយកទោសម្លាប់ចោលដែនការគេសម្លាប់៨០នាក់ខាងយោធាសម្លាប់ទាំងស្រីទាំងប្រុស ។

វណ្ណៈ៖ ខាងនិរតីសម្លាប់?

សុីង៖ ចាស!ដូចមិនមែនខាងនិរតីទេ ដូចជាខាងណាទេ អ្នកនៅរោងចក្រជាមួយគ្នានិងឯងប៉ុនគេមិនមែននៅខេត្តនិរតីទេ បែបពួកបស្ចឹមហ្នឹងឯង ។

វណ្ណៈ៖ ចឹងមីងនៅទិវ៉ាល់ហ្នឹងមីងនៅធ្វើស្រែទៀតមីងអត់រត់មកទៀតទេ?

សុីង៖ ខ្ញុំមកហ្នឹងចុះមកជួយប្រជាជន ។

វណ្ណៈ៖ បាទ ។

សុីង៖ ពេលយួនបុកមកយើងនៅជួយប្រជាជនមួយរយៈចឹងពេលយួនបុកមកយើងរត់ចឹងទៀត ។

វណ្ណៈ៖ បាទ ។

សុីង៖ តែពួកខ្ញុំរត់ជិះឡានរហូត ឡានតា ម៉ុក១៥ដឹករហូត ១៥ឡាន ។

វណ្ណៈ៖ ចឹងមកជាមួយតា ម៉ុក?

សុីង៖ ចាស!ពេលដល់កន្លែងសំណាក់គាត់ទុកហ្នឹងទៅ ពេលយួនចូលរត់ទៀតទៅ ទើបដើរពីបវេលមកព្រំដែននេះទេបានដើរ កាលមកពីនោះមិនមានដើរផង ។

វណ្ណៈ៖ ចឹងកាលនៅបវេលរយៈពេលប៉ុន្មានដែរ?

សុីង៖ នៅមានយូរអីបួនប្រាំថ្ងៃៗហ្នឹងណាស់ ។

វណ្ណៈ៖ បាទ!រត់តាមផ្លូវរហូតអស់រយៈពេលប៉ុន្មានបានមកដល់ព្រំដែនមួយខែ?

សីងៈ រាប់ខែមិនត្រឹមមួយខែទេ ចុះយើងនៅនោះបួនដប់ថ្ងៃទៅយើងនៅនេះបួនដប់ថ្ងៃទៅ បើយួនមិនបុកទៅយើងនៅបានយូរទៅ បើយួនបុកយើងមកទៀតមក ។

វណ្ណៈ: ចឹងបីបួនខែ?

សីងៈ ចាស! យើងមិនបានផ្លៀងផ្ទាត់ផង ។

វណ្ណៈ: ចឹងពេលរត់មកតាមផ្លូវនិងមីងមានឃើញគេស្លាប់តាមផ្លូវដោយសារអត់អាហារអីទេ?

សីងៈ កាលដែលខ្ញុំរត់តាមផ្លូវហ្នឹងអត់មានទេ ។

វណ្ណៈ: អត់មានទេ?

សីងៈ មានកាលនៅខិវ៉ាល់នោះឃើញគេសម្លាប់មនុស្សរបណ្ដោយ ។

វណ្ណៈ: បាទ ។

សីងៈ បើថារត់មកអត់មានឃើញងាប់តាមផ្លូវទេ ទាល់តែដល់ព្រំដែននេះយើងឈឺស្លាប់បណ្ដោយហ្នឹង ។

វណ្ណៈ: ឈឺដោយសារអី?

សីងៈ ដោយសារអត់បាយអត់អីរត់មកដល់ដីថៃហ្នឹងអត់បាយអត់ទឹកចឹងហើយឈឺគ្រុនចាញ់ស្លាប់ទៅស្រីប្រុសអី ជំនាន់ហ្នឹងគ្រុនចាញ់និងដាច់ពោះហ្នឹង ខ្លះងាប់នៅលើអង្រឹងក៏មាន ។

វណ្ណៈ: ចឹងកាលមីងរត់មកដល់ដំបូងមីងរត់មកដល់ណាមុនគេ?

សីងៈ ខ្ញុំខាងចំការបេកនោះ ។

វណ្ណៈ: ចំការបេកនៅខាងណាវិញ?

សីងៈ ចំការបេកនៅខាងម៉ាឡៃយើងនេះរស់នៅហ្នឹងឯង ។

វណ្ណៈ: ចឹងមកដល់សាស្ដារចឹងដំបូងគេរៀបចំកំលាំងយ៉ាងម៉េចទៅ?

សីងៈ គេរៀបកំលាំងដឹកជញ្ជូន ។

វណ្ណៈ: ក្រុមដឹកជញ្ជូនដឹកជញ្ជូនអីខ្លះ?

សីងៈ ដឹកជញ្ជូនគ្រាប់អង្ករសម្ភារខោអាវស្អីៗរបស់តែពទាំងអស់ ។

វណ្ណៈ: ចឹងកាលហ្នឹងប្រុសៗបានគេឲ្យទៅសមរភូមិមុខស្រីៗនៅក្រោយ?

សីងៈ ស្រីៗនៅដឹកជញ្ជូនដាប់តែសមរភូមិហ្នឹងដែលណាស់ ។

វណ្ណៈ: ចឹងមានស្រីៗឡើងវ៉ៃឡើងបាញ់ទេ?

សីងៈ អត់មានទេ មានតែដឹកជញ្ជូន ដឹកជញ្ជូនមកវិញមានរបួសសែងមកអ្នកជំងឺគ្នាយើងឈឺក៏សែងមក ។

វណ្ណៈ	មីងមានឃើញមានរបួសច្រើនទេទ័ពយើងទ័ពខាងខ្មែរក្រហមហ្នឹង?

សីង:	កម្រណាស់ទៅដឹកជញ្ជូនបីបួនដើងមិនទាន់មានរបួសមួយផងច្រើនសែងស្រីៗមកគ្នាឯងវិញ ។

វណ្ណៈ	យ៉ាងម៉េចចឹង?

សីង:	ឈឺ ។

វណ្ណៈ	ចឹងនៅពេលដើរលុកព្រៃអត់មានខ្លាចពស់សត្វខ្លាដីរអីទេ?

សីង:	ដល់ចឹងធម្មតាអត់មានខ្លាចទេ ។

វណ្ណៈ	មានដែលជួបទេ សត្វអស់ហ្នឹង?

សីង:	ហូបទៀតផង ទ័ពបាញ់ឲ្យហូបដល់ចឹងធម្មតាខ្ញុំទៅខ្លះចឹងយួនកន្ទ្រាក់មីនមានរបួសស្រីៗក៏សែងទៅ ។

វណ្ណៈ	ចឹងទាហានយួនមានស្លាប់ច្រើនទេ?

សីង:	រឿងស្លាប់មានស្លាប់ច្រើនហ្នឹងឯង ។

វណ្ណៈ	ចឹងមីងនៅសាស្តារខាងម៉ាឡៃនោះវិញ?

សីង:	ចាស ។

វណ្ណៈ	កាលហ្នឹងប្រធានកងពលពីណាគេ?

សីង:	កាលម៉ាជំនាន់ហ្នឹងខ្ញុំមិនសូវស្គាល់ទេ ។

វណ្ណៈ	ចឹងអត់ស្គាល់តា ហុង តា សុខភាពអីទេ?

សីង:	តា ហុងហ្នឹងនៅខាងភូមិដូង ។

វណ្ណៈ	ភូមិដូងម៉ាឡៃ?

សីង:	ចាស ។

វណ្ណៈ	ចឹងខាងសាស្តារពីណាគេ?

សីង:	នាយ កនយើងនេះ តា កនអីហ្នឹងឯងនៅជាមួយគ្នាហ្នឹង ។

វណ្ណៈ	ចឹងខាងសាស្តារតា កនអី?

សីង:	ចាស ។

វណ្ណៈ	ចឹងកាលហ្នឹងមីងមានបានរត់ទៅជំរំអីទេ?

សីង:	ជំរំនេះមានខ្ញុំមិនបានចូលទៅផងហ្នឹង ។

វណ្ណៈ	ចឹងកាលហ្នឹងមីងអត់មានបំណងរត់ទៅជំរំរត់ទៅជាយដែនរត់ទៅស្រុកក្រៅអីទេ អត់មានគិតចឹងទេ?

សីផៈ  កាលហ្នឹងអ្នកឈឺខ្ញុំកាលហ្នឹងឈឺដេកនិងកន្ទេលឡានគេមកយកដឹកឡានកាកបាទគេមកយកដាក់ឡានទៅប្រទេសក្រៅខ្ញុំមិនទៅផង  ខ្ញុំសុខចិត្តលូនតាមព្រៃស្បៀវមកវិញ  ខ្ញុំអត់ទៅបើទៅសំណាងបាត់ហើយតែអត់ដឹង ។

វណ្ណៈ  បើទៅចោលពូ?

សីផៈ  កាលហ្នឹងអ្នកឈឺៗទៅទាំងអស់  ឲ្យតែអ្នកឈឺ ។

វណ្ណៈ  បាទ ។

សីផៈ  ឡានគេមកដល់ថ្នល់ក្រហមគេនៅនោះ ។

វណ្ណៈ  ចឹងសុខចិត្តលូនគេចវិញ?

សីផៈ  គេចនាំគ្នារត់សុទ្ធកាន់ឈើប្រត់នោះ ។

វណ្ណៈ  កាលហ្នឹងមកមានពួកបារាំងមានពួកបរទេសអីចឹង?

សីផៈ  កាលវៀត្នាហ្នឹងមានចិនមានអីចូលសមរភូមិថត ។

វណ្ណៈ  យ៉ាងម៉េចបានជាមីងខ្លាចភ័យមិនចង់ទៅស្រុកគេ?

សីផៈ  ចុះខ្លាចបែកគ្នាឯងធ្លាប់រស់នៅជាមួយគ្នាដូចជាបងប្អូន ។

វណ្ណៈ  ចឹងសុខចិត្តនៅក្នុងព្រៃញាំក្តួចទៀតចុះ?

សីផៈ  ចាស! នៅហូបបបរអីចឹងទៅ ។

វណ្ណៈ  ចឹងមីងរៀបការជាមួយពូនៅឆ្នាំណាវិញ?

សីផៈ  រៀបកាលហ្នឹងគេមិនទាន់ផ្តាច់ខ្លួនទេ  ឆ្នាំប៉ុន្មាន ។

វណ្ណៈ  ចឹងឆ្នាំ៧៩មីងមិនទាន់រៀបទេ?

សីផៈ  នៅទេ  ទើបនិងរៀបដែលហ្នឹងណាស់ ។

វណ្ណៈ  ប៉ុន្មានឆ្នាំបានមីងរៀប?

សីផៈ  យី! ការបាន២៧ឆ្នាំហើយ ។

វណ្ណៈ  ចឹងកាលមីងការជាមួយពូហ្នឹងមានលោកមានភ្លេងប្រពៃណីអីទេ?

សីផៈ  អត់ទេ  ការនៅជំរំនេះតើ ។

វណ្ណៈ  គេហៅជំរំអីគេ?

សីផៈ  ជំរំតា  ង៉ុកនេះ  ជំរំហ្នឹងគ្រាន់តែទៅបើកអង្គរស៊ី ។

វណ្ណៈ  តែកាលមីងរៀបការជាមួយពូហ្នឹងស្គាល់ចិត្តគ្នា?

សីផៈ  ចាស ។

វណ្ណៈ	មិនមានគេបង្ខំទេពេលហ្នឹង?

សឹង:	អត់ទេ  អត់មានពីណាបង្ខំទេ  មានមេគេចូលសួរយើងធម្មតាទៅការជំរំមានក្នុងគេសៀកពាក់ធម្មតាចឹង ។

វណ្ណៈ	ចឹងមីងមានពាក់ក្នុងអីធម្មតាគ្រាន់អត់មានលោកសង្ឃ?

សឹង:	អត់មានលោកសង្ឃអត់មានភ្លេងអត់មានស្អី ។

វណ្ណៈ	ចឹងមានតា  អាចារ្យទេ?

សឹង:	មានចាស់ៗអាចារ្យឡូពរ ។

វណ្ណៈ	ហើយជប់លៀងហូបចុកយ៉ាងម៉េចដែរ?

សឹង:	ហូបមានអីកាលជំនាន់ហ្នឹងមានមាន់មីនអីហ្នឹង ។

វណ្ណៈ	មាន់មីនយ៉ាងម៉េចទៅ?

សឹង:	អាមាន់ឆ្អឹងនោះ ។

វណ្ណៈ	គេហៅមាន់មីន?

សឹង:	ចាស!ហើយយើងទិញមាន់បន្តិចបន្តួចធ្វើទៅ  ចាស់ៗពីរបីនាក់ទៅ ។

វណ្ណៈ	អត់មានចងដៃជាលុយកាក់អីទេ?

សឹង:	អត់ ។

វណ្ណៈ	ចឹងដូចជាជប់លៀងចឹង?

សឹង:	ចាស ។

វណ្ណៈ	មានមេៗចូលរួមដែរ?

សឹង:	កាលហ្នឹងទៅការជំរំមានមេណាទៅអត់ផង ។

វណ្ណៈ	កាលហ្នឹងប៉ុន្មានគូរកាលការ?

សឹង:	អត់ទេ  ការម្នាក់ៗហ្នឹង ។

វណ្ណៈ	ខ្លះកាលឆ្នាំ៨៣-៨៤មានបងប្អូនខ្លះការម្តងមាន៦គូរអីមានដែរ?

សឹង:	មានដែរ ។

វណ្ណៈ	តែគាត់និយាយថា  អត់មានបង្ខំទេ?

សឹង:	យើងស្រឡាញ់គ្នា  យើងគេស្នើអីត្រឹមត្រូវបានគេចាប់ដៃឲ្យ ។

វណ្ណៈ	បាទ!ចឹងមីងមកដល់ឥឡូវដូចថា  ពេលមីងរត់មកដល់ក្នុងព្រៃហើយដូចថាមកឃើញព្រៃធំៗមើលពន្លឺថ្ងៃមិនចឹងឃើញអីចឹងមានទឹកស្រណោះផ្ទះទេ ដល់ពេលចឹង?

សឹង៖ ដល់ចឹងទៅដូចជាធម្មតា អត់មានទឹកឃើញទៅម៉ែឪអី ចេះតែនាំគ្នាធ្វើរោងអីនាំកូនចៅនៅចេះកាប់ព្រៃបណ្ដើរទៅ ។

វណ្ណៈ៖ បាទ ។

សឹង៖ យូរៗទៅវាស្រឡះ ។

វណ្ណៈ៖ មីងមានខ្លាចមីនអីទេកាលហ្នឹង?

សឹង៖ ខ្លាចសុទ្ធតែមីនម្ដុំហ្នឹង ម្ដុំអស់ហ្នឹងសុទ្ធតែមីនហើយ ។

វណ្ណៈ៖ ចឹងនៅពេលដើរជញ្ជូនគ្រាប់ជញ្ជូនអង្ករទៅសមរភូមិអីមានភ័យទេពេលដើរ?

សឹង៖ អត់ធម្មតាដល់ចឹងអត់មានខ្លាច បើមិនគេយើងបើមិនគេងាប់យើងងាប់ ។

វណ្ណៈ៖ គិតចឹងបណ្ដោយ?

សឹង៖ ចាស!គិតឃើញអាយុគេថ្ងៃប៉ុន្មានយើងថ្ងៃដូចតែគ្នាហ្នឹង ដល់ចេញពីកន្លែងហើយអត់មានគិតងាប់រស់សប្បាយបណ្ដោយ ។

វណ្ណៈ៖ ចឹង?

សឹង៖ កាលដែលខោអាវចិនបើកហ្នឹង ធ្វើស្រោមជើងកងកង់ៗដើរកាត់ទឹកបណ្ដោយ ទៅដល់ជួបទ័ពចឹងសប្បាយ ។

វណ្ណៈ៖ ចឹង?

សឹង៖ មានម្ហូបអីហាលទុកឲ្យយើងដាក់សាក់កាដូមកវិញ មកហូបកន្លែងយើងវិញ ។

វណ្ណៈ៖ ចឹងមានសត្វព្រៃ?

សឹង៖ ចាស!សុទ្ធតែសត្វព្រៃហើយយើងទៅកាលហ្នឹងមានស្ពឺចិនបើកអង្ករបើកស្ពឺៗឲ្យយើងហូបហ្នឹងយើងធ្វើនំធ្វើអីទៅ ខ្លាញ់អីតាំងឡាំងៗខ្ទះអីហូបសណ្ដែកបាយអីយើងធ្វើផ្ញើទ័ព ។

វណ្ណៈ៖ ចឹងកាលមីងនៅសាស្ដាហ្នឹងមានមនុស្សច្រើនទេមានទ័ពមានច្រើន?

សឹង៖ ទ័ពមានច្រើនហ្នឹងហើយ តែវាមិនមានផ្ទះកាលហ្នឹងមានខ្ទមៗចងអង្រឹងដេកប្រកកៅស៊ូ ។

វណ្ណៈ៖ ចឹងមីងនៅសាស្ដារហូតដល់ឆ្នាំណាបានមីងមកនៅនេះ?

សឹង៖ សាស្ដាមិនបាននៅជាប់ដងម្ដងនៅចំការចេកទៅ នៅគ្រប់កន្លែងខ្ញុំមិនបាននៅជាប់ទេ ទើបបានប្ដីនៅជាប់នេះ ។

វណ្ណៈ៖ ចឹងខាងម៉ាឡៃភូមិដូងអីមាននៅទេ?

សឹង៖ ធ្លាប់ដែលតែនៅមួយរយៈមួយខែពីរខែអី ទៅគ្រប់កន្លែងមាននៅមួយកន្លែងណាដឹកជញ្ជូន ។

វណ្ណៈ៖ អរ! ។

សឺផ:	គេត្រូវដឹកជញ្ជូនទៅប៉ៃលិនទៅប៉ៃលិនទៅ ដល់ហើយមកវិញទៅអត់មាននៅមួយកន្លែងទេ គេរើសទៅកោះកុងខ្ញុំមិនបានទៅនិងគេ ទើបមានប្តីនៅមួយកន្លែងកាលនៅនារីមាននៅមួយកន្លែងណានៅដេកកៅអគ្រឹង១ហ្នឹង ។

វណ្ណៈ:	ចឹងកាលពីដំបូងយើងមានតែកៅស៊ូយើងមិនហ៊ានធ្វើផ្ទះអីទេ ព្រោះទីតាំងមិនពិតប្រាកដ?

សឺផ:	ហ្នឹងហើយមិនពិតប្រាកដ ។

វណ្ណៈ:	ចឹងមីងមីននៅសាស្តាមានច្រើនទេ?

សឺផ:	មានច្រើនដែរ យើងទៅចឹងទ័ពគេរាវមីនអីចឹងទៅណាស់ ។

វណ្ណៈ:	ចឹងមីងហ្នឹងមិនមែនតែខាងយួនទេខាងខ្មែរក្រហមក៏ដាក់ដែរ?

សឺផ:	ខ្មែរក្រហមច្រើនជាងយួនទៀត ។

វណ្ណៈ:	ចឹងដាក់ទាំងសងខាងដល់ពេលត្រូវរបួសត្រូវទាំងអស់គ្នា?

សឺផ:	ចាស!ពូអើយមនុស្សយើងថ្លៃណាស់ មិនមែននេះទេខ្ញុំកាលនៅនោះយួនចូលពេញព្រំដែនពួកខ្ញុំដឹកជញ្ជូនទៅជាប់នៅនោះ ត្រង់ណាក៏ផ្លូវក៏ផ្លូវ«ក៥»ៗ ។

វណ្ណៈ:	បាទ ។

សឺផ:	ហើយសុទ្ធតែមីនចឹងប្រឡោះពូងឯឈានមួយខ្ញុំឈានមួយឲ្យចំដានគ្នាហ៊ានតែខុសមីនស្គរ ។

វណ្ណៈ:	ចឹងអ្នកដើរមុនមិនមានគ្រោះថ្នាក់ជាង?

សឺផ:	អត់ទេ អ្នកមុនដើររាវឲ្យយើង ដឹងកន្លែងណាមានមីនមិនមានមីនគេបោះជំហានឲ្យយើងដើរ ។

វណ្ណៈ:	បាទ ។

សឺផ:	ដូចនារីពីរចឹងយុវជនមួយៗគេឲ្យឆ្លាស់គ្នា ។

វណ្ណៈ:	ចឹងបើមិនធ្វើចឹងជាន់មីនផាប់?

សឺផ:	ចាស!បើថាវាបាញ់មកយើងដឹកដៃរត់ ។

វណ្ណៈ:	ចឹងដល់រត់ចឹងយើងយ៉ាប់?

សឺផ:	ចាស ។

វណ្ណៈ:	ចឹងនៅពេលយួនបាញ់ប្រាវៗចឹងនៅពេលរត់ហ្នឹងមានគ្រោះថ្នាក់អី?

សឺផ:	អត់ ចុះមានទ័ពនៅខាងមុនហើយ ។

វណ្ណៈ:	ចឹងកាលហ្នឹងមីងមានដឹងថាយួនដកទៅវិញនៅឆ្នាំណាទេ?

សឺផ:	យួនដកមិនដឹងជាឆ្នាំណាទេ ភ្លេចអស់ហើយ ។

វណ្ណៈ ចឹងនៅពេលដែលយួនដកចេញពីស្រុកខ្មែរយើងទៅហើយនៅសល់តែខ្មែរវិជាមួយខ្មែរ នៅពេលហ្នឹងសង្គ្រាមថមថយមិនសូវច្បាំងគ្នាខ្លាំងឬនៅមានការច្បាំងគ្នាខ្លាំងដដែល ។

សឹង: ខ្ញុំដូចជាមិនដឹង ដឹងតែគេផ្តាច់ខ្លួនឈប់បណ្តោយនិងឯង ។

វណ្ណៈ ចឹងការផ្តាច់ខ្លួនហ្នឹងសម្តេចហ៊ុន សែនមកដែលឬយ៉ាងម៉េចឬមីងមិនបានទៅចូលរួមទេ?

សឹង: ខ្ញុំមិនបានទៅទេ ។

វណ្ណៈ ចឹងគេទៅតែមេៗ?

សឹង: ចាស ។

វណ្ណៈ ចឹងនៅខាងនេះ តា សុន សេនគាត់មកគ្រប់គ្រងនៅនេះដែរ?

សឹង: គាត់យូរៗគាត់មកម្តងចឹង គាត់មានមកជាប់ដង ។

វណ្ណៈ ចឹងតា កន?

សឹង: បើតា កនកន្លែងគាត់នៅ៣២គាត់នៅប្រចាំការបណ្តោយ ។

វណ្ណៈ ចឹងនៅភ្នំព្រីកនេះមានពីណាគេ?

សឹង: មានតែតា កនហ្នឹងឯងក្តោបក្តាប់ទាំងអស់ ពេលសុន សេនចាប់មកចាប់មានសម្ងាប់នៅពេលហ្នឹងទៀត ។

វណ្ណៈ បាទ!ចឹងនៅពេលសុន សេនចូលមកមានការតឹងតែងប្រជាជនពិបាកមួយសារទៀត?

សឹង: រៀងពិបាកជាងមុន ។

វណ្ណៈ បាទ!តែកាលហ្នឹងមិនទាន់មានផ្ទះចឹងៗដែរ?

សឹង: អត់មានទេ ។

វណ្ណៈ មានតូចៗអី?

សឹង: មានផ្ទះនៅតាមព្រំដែននោះ ។

វណ្ណៈ ចឹងនៅនេះអត់មានទេ?

សឹង: ចាស ។

វណ្ណៈ ចឹងព្រៃសុទ្ធសាធតែម្តង?

សឹង: ហ្នឹងព្រៃទាំងអស់ នៅនេះដល់ផ្តាច់ខ្លួនទៅបាននាំគ្នាចាប់ដីធ្វើទៅ ។

វណ្ណៈ ចឹងមីងមានដឹងថាអស់ព្រៃនៅឆ្នាំណាដែរ?

សឹង: មិនដឹងអស់នៅឆ្នាំណា ។

វណ្ណៈ សមាហរណ៍កម្មហើយបានអស់?

សីង៖ ព្រៃទើបអស់ដែលហ្នឹងណាស់ ទើបអស់ប្រហែលជា៦ទៅ៧ឆ្នាំហ្នឹងឯង ។

វណ្ណៈ៖ ចឹងនៅហ្នឹងមានអង្គការស៊ីម៉ាកជួយដោះមីនអត់យកលុយទេមែនទេ?

សីង៖ ដោះអត់យកលុយផង ដីខ្ញុំនៅក្រោយហ្នឹងសុទ្ធតែមីនស៊ីម៉ាកដោះជួយមានយកលុយយកកាក់អី ។

វណ្ណៈ៖ បាទ ។

សីង៖ ជួយអ្នកក្រីក្រ ។

វណ្ណៈ៖ ហ្នឹងជាអង្គការគេជំនួយមកពីប្រទេសក្រៅដែរ?

សីង៖ ចាស ។

វណ្ណៈ៖ ដូច្នេះគេមិនយកលុយទេ?

សីង៖ ចាស ។

វណ្ណៈ៖ ចឹងការរស់នៅហ្នឹងមីងគិតមើល កាលមិនទាន់ផ្គាច់ខ្លួននិងផ្គាច់ខ្លួនហើយចឹងតើការរស់នៅរបស់ប្រជាជនមានលក្ខណៈយ៉ាងម៉េចដែរ វាមានលក្ខណៈងាយស្រួលយ៉ាងម៉េចដែរ?

សីង៖ កាលមិនទាន់ផ្គាច់ខ្លួនមានពិបាកអីបើអង្គរដ្ឋទាំងអស់ ។

វណ្ណៈ៖ ចឹង?

សីង៖ យើងមិនមានលុយកាក់អីទិញស៊ីអត់ ។

វណ្ណៈ៖ ចឹងកាលហ្នឹងស្រួលជាងឥឡូវ?

សីង៖ កាលហ្នឹងមានពិបាកអី ។

វណ្ណៈ៖ ចឹងឥឡូវយើងពិបាកជាងវិញ?

សីង៖ ឥឡូវយើងលុយកាក់យើងយកទិញហូបខ្លួនយើង កាលហ្នឹងអង្គការចិញ្ចឹមទាំងអស់ហ្នឹង ទាំងបីពេលស្អីៗទាំងអស់ ។

វណ្ណៈ៖ បាទ ។

សីង៖ យើងមានហត់អីចាំតែបើកហូបបណ្ដោយ ។

វណ្ណៈ៖ បាទ!ចាំតែបើកហូបតែមីងគិតថា ការរស់នៅរបៀបចឹងវាស្រួលជាងឥឡូវឬឥឡូវហ្នឹងស្រួលជាងកាលហ្នឹង?

សីង៖ កាលហ្នឹងរបស់បើកយើងចង់ឆ្ងាយវាមានអីឆ្ងាញ់ យើងចង់ឆ្ងាញ់ទាល់យើងទៅជញ្ជាត់កំពីសអីហើយបើឲ្យតែយើងមានលុយហូបអីក៏ឆ្ងាញ់ ។

វណ្ណៈ	តែនិយាយភាពងាយស្រួលការរស់នៅវិញ មីងចង់បានរបៀបហ្នឹងវិញឬចង់បានពីឥឡូវទៅមុខទៀត ចង់ឲ្យត្រឡប់នៅរបៀបមុន?

សីង:	អត់ទេ មិនចង់ទៅរបៀបមុនទេ មករបៀបឥឡូវនេះស្រួលណាស់ ។

វណ្ណៈ	ចឹងមីងថាកាលនោះស្រួលហូប?

សីង:	កាលហ្នឹងវាស្រួលម្យ៉ាង កាលហ្នឹងវាមិនទាន់មានចេះ ។

វណ្ណៈ	ហ្នឹងហើយ ។

សីង:	ឥឡូវយើងមានចេះហើយទៅរកដូចមុនយ៉ាងម៉េចកើត ។

វណ្ណៈ	ស្មានថាយើងមានសិទ្ធសេរីភាពដើរចេះហើយមីងថាចឹងវារញ៉េរញ៉ៃមិនល្អទៅរករបបហូបវិញវាល្អជាងអីចេះ ខ្ញុំចមីងគិតចឹងវិញណាស់ ។

សីង:	ខ្ញុំមិនគិតទៅចឹងវិញទេ ។

វណ្ណៈ	បាទ ។

សីង:	ឲ្យស្រួលចេះរហូតទៅកុំឲ្យពិបាក កុំឲ្យមានសង្គ្រាមអីទៀតពិបាកកូនចៅណាស់ ខ្ញុំចាស់ហើយមិនគិតទេ គិតក្មេងជំនាន់ក្រោយវាពិបាក ។

វណ្ណៈ	បាទ ។

សីង:	ចង់ឲ្យស្រួលចឹងរហូទៅ កុំឲ្យមានសង្គ្រាមមានអីទៀតទេ ។

វណ្ណៈ	ចឹងគិតមីងវិញមីងមានគិតថាអាចមានសង្គ្រាមកើតឡើងរវាងខ្មែរនិងខ្មែរទៀតទេ?

សីង:	ខ្ញុំមិនដឹងយ៉ាងម៉េច យើងថាមិនមានទៅលោវាមានវាពិបាកដែរ ។

វណ្ណៈ	ចឹងលើកមុនយើងមានធ្វើសង្គ្រាមឆ្នាំ៧០អីដោយសារថា យើងមិនបានយល់អីតែឥឡូវកាលលើកមុនដោយសាថាសេនាប្រមុខលន់ នល់គាត់ទម្លាក់សម្តេចសីហនុ?

សីង:	ចាស ។

វណ្ណៈ	ចឹងយើងឹងយើងចង់ឲ្យសម្តេចសីហនុមកកាន់គ្រប់គ្រងប្រទេសវិញ ចឹងយើងចូលចលនា ចុះឥឡូវនេះដល់ពេលនេះ ឧទាហរណ៍ថាសម្តេចប្រកាសថាកូនព្រៃចូលព្រៃម្តងទៀត មីងអាចទៅទៀតទេ?

សីង:	ទៅ ។

វណ្ណៈ	មានព្រៃណាចូលឥឡូវ?

សីង:	តែតស៊ូតទៀតហើយ ។

វណ្ណៈ	ចឹងចង់តទៀត?

សីង៖ ចាស ។

វណ្ណៈ៖ ចឹងវៃខ្មែរនិងខ្មែរមីងទៅទៀត?

សីង៖ ទេ អត់មានវៃខ្មែរនិងខ្មែរទេខ្លាចតែប្រទេសក្រៅគេចូលលុកលុយតែខ្មែរអត់ទេ ។

វណ្ណៈ៖ ចឹងខ្មែរវៃខ្មែរឈប់ហើយ?

សីង៖ ខ្មែរវៃខ្មែរឈប់ហើយផ្អាកហើយ ។

វណ្ណៈ៖ ចឹងបើវៃជាមួយបទេសទៅទៀត?

សីង៖ ទៅទៀតអាហ្នឹងកូនជំនាន់ក្រោយគេតស៊ូទៀតហើយ ជំនាន់ម៉ែផ្អាក ។

វណ្ណៈ៖ ព្រោះម៉ែឆ្អែតហើយ ។

សីង៖ ឆ្អែតហើយ ខ្មែរនិងខ្មែរវៃធ្វើអីទៀត ។

វណ្ណៈ៖ បាទ ។

សីង៖ វាអស់ចិត្តអស់ចង់ហើយឲ្យឆ្អែតហើយ ។

វណ្ណៈ៖ បើខ្ញុំគិតវិញថាវាមិនមានបញ្ហាទៀតទេ សម្រាប់ខ្មែរនិខ្មែរ?

សីង៖ ចាស!ខ្លាចតែប្រទេសគេ ។

វណ្ណៈ៖ យើងអាចនៅជួបបញ្ហាជាមួយប្រទេសដទៃ?

សីង៖ ចាស ។

វណ្ណៈ៖ ឥឡូវយើងគិតមើលខ្មែរនិងខ្មែរគ្មានពីណាមកបញ្ចុះបញ្ចូលទៀតទេ គេយល់អស់ហើយដល់សម័យកាលនេះហើយ?

សីង៖ គេយល់អស់ហើយ ឥឡូវគេរកតែមានគេរកតែបាន ។

វណ្ណៈ៖ បាទ!ឥឡូវមានតស៊ូឲ្យពីណាទៀត?

សីង៖ ចាស ។

វណ្ណៈ៖ តស៊ូឲ្យគេឈ្នះគេមានលុយគេមានអំណាចទៀតហ្នឹង?

សីង៖ យើងអត់ដដែលហ្នឹង ។

វណ្ណៈ៖ យើងនៅជួយវៃអត់ដែលហ្នឹង?

សីង៖ អត់ដដែលហ្នឹង ។

វណ្ណៈ៖ ចឹងយើងកុំតស៊ូបើជាមួយបរទេសយើងទៅទៀត?

សីង៖ យើងការពារទឹកដីកុំឲ្យតែគេមកយកទឹកដីខ្មែរទៅបានហើយ ។

វណ្ណៈ ចឹងយើងនៅនេះបីបួនឆ្នាំទៀតថ្មល់ជាតិក្ងីងហើយ យើងចង់ទៅលេងស្រុកវៃព្រវែងស្មាយ រៀងតាកែអ៊ីប្រហែលជាឆាយហើយ?

សីង: ចាស ។

វណ្ណៈ ឧបមាថាមានឡានក្រុងអ៊ីមិនសូវជាអស់សាហ៊ុយប៉ុន្មានដែរ?

សីង: ចាស ។

វណ្ណៈ កាលពីមុនទាល់តែមាន១០ម៉ឺនក្នុងមួយនាក់បានទៅដល់ស្រុក?

សីង: ចាស!ខ្ញុំទៅធ្វើបុណ្យឲ្យម៉ែឡើងមិនចេះតិច មកដល់ផ្ទះវិញយកលុយឲ្យថ្លៃឡាន ។

វណ្ណៈ បាទ ។

សីង: ខ្ញុំឆ្ងាយពេកវាចុះសាហ៊ុយទៅគ្នាច្រើនវាអស់លុយច្រើន ។

វណ្ណៈ បាទ!តែទៅថ្ងៃខាងមុនទៀតមានឡានក្រុងអ៊ីប្រហែលជាមិនសូវអស់សាហ៊ុយប៉ុន្មានទេ?

សីង: ចាស ។

វណ្ណៈ ចឹងកាលមីងមករស់នៅទីនេះហើយចាប់មានភូមិកំណើតមានដីធ្លីនៅនេះ មីងមានចង់ទៅរស់នៅស្រុកកំណើតវិញដែរ ។

សីង: អត់ ម៉ែឪចែកដីឲ្យមិនទៅផងលោមឲ្យទៅនៅស្រុកកំណើតវិញអត់ ។

វណ្ណៈ ចឹង?

សីង: មិនទៅជុំបងប្អូននៅតែឯងស្រួលជាង ។

វណ្ណៈ ចឹងមីងមិនបានទៅដកពិសោធន៍ទៅនិងមួយគ្រាសិនទេ?

សីង: ទៅលើកមុនតែមួយខែក្តុំហើយមកវិញនេះ ខ្ញុំមិនចេះនៅផង ។

វណ្ណៈ យ៉ាងម៉េចបានជាមិនចេះនៅ?

សីង: ទៅដល់ចឹងទៅឃើញគេដឹកស៊ីៗពេកវាធុញ ។

វណ្ណៈ បាទ ។

សីង: មកយើងនិងមានស្ងាត់ស្ងៀមណាស់ ។

វណ្ណៈ បាទ!ចឹងទៅនោះធ្វើតែស្រែហើយទំនេរ?

សីង: ធ្វើស្រែហើយទំនេរ មានតែទឹកទន្លេមកហូរមកមួយឆ្នាំធ្វើម្តង មានតែអង្គុរម៉ែឲ្យមកនៅជាមួយតែគាត់មិនមក ។

វណ្ណៈ គាត់ចាស់ហើយគាត់មិនមកចោលភូមិកំណើតទេ?

សីង: កូនច្រើននៅនោះយើងមកក្បាលមួយតែឯង ។

វណ្ណៈ៖ បាទ ។

សីផៈ បើឪខ្ញុំគាត់ស្លាប់  ឪខ្ញុំបានមកម្តងមុនគាត់ស្លាប់ ។

វណ្ណៈ៖ បាទ ។

សីផៈ គាត់ធ្វើបុណ្យឲ្យខ្ញុំមិនចេះតិចដែរហើយនោះ ។

វណ្ណៈ៖ គាត់ស្មានថាស្លាប់បាត់ហើយ?

សីផៈ ស្មានថាស្លាប់បាត់ហើយ ។

វណ្ណៈ៖ ចឹងកាលឃើញទៅវិញមានការភ្ញាក់ផ្អើលយ៉ាងម៉េចទៅពេលឃើញទៅវិញ?

សីផៈ ដុបលៀងដូចអីចឹង ។

វណ្ណៈ៖ ជីដូនមួយជីដូនពីអីមកអស់ហើយ?

សីផៈ មកទាំងអស់គ្នាធ្វើបុណ្យធ្វើទាន  បងប្អូនបានតែយូរៗទៅម្តងសប្បាយ ។

វណ្ណៈ៖ ចឹងនៅទីនេះមានតែព្រៃស្ងាត់គ្មានផ្ទះគ្មានសំបែងពីមុនមកមានភូមិចាស់អីទេ  សម័យលន់  នល់ សម័យសង្គ្រាមអី?

សីផៈ អត់មានទេ ។

វណ្ណៈ៖ ឥឡូវមានកើតជាភូមិតាមដាយដែនហើយ  បើថៃចង់មកយកក៏យកមិនកើតដែរ  យើងនៅពេញហើយចឹងជាការមួយល្អដែរយើងមានភូមិមានផ្លូវថ្នល់អីចឹង?

សីផៈ ចាស ។

វណ្ណៈ៖ ចឹងប្រជាជននៅភូមិស្រុកហ្នឹងគេបង្កើតមុខរបរអីជាប្រចាំ?

សីផៈ គេធ្វើចំការដាំពោតដាំសណ្តែកដំឡូងអ្នកចំការមានតែប៉ុណ្ណឹង ។

វណ្ណៈ៖ បាទ!ចឹងផលដំណាំដែលប្រជាជនធ្វើបានយកទៅលក់ខាងណា?

សីផៈ លក់ឲ្យថៃផងខ្មែរផង ។

វណ្ណៈ៖ ចឹងឆ្នាំនេះផលដំណាំដែលធ្វើបានដូចជាដំឡូងមានតម្លៃគួសមដែរ?

សីផៈ បានដំឡូងស្ងួតនោះ៥បាត  ដំឡូងស្រស់ទៅ៣បាតចឹងទៅណាស់ ។

វណ្ណៈ៖ បាទ!ហើយឆ្នាំនេះខ្ញុំមកតាមផ្លូវតាំងពីបវេលថ្មគោលអីហ្នឹងឃើញដាំច្រើនណាស់  ឆ្នាំនេះមិនដឹងតម្លៃបានប៉ុន្មានទៀតទេ?

សីផៈ គេថានៅថ្លៃមួយឆ្នាំពីរទៀត ។

វណ្ណៈ៖ បើសិនជាបានថ្លៃទៀតប្រជាជននៅនេះរស់នៅបានស្រួស?

សីផៈ ចាស ។

វណ្ណៈ: មិនជួបការលំបាកអីប៉ុន្មាន?

សីង: ចាស! ឲ្យតែបានថ្ងៃស្រួលហើយ ។

វណ្ណៈ: ក្រៅពីការងារដូចជាដាំដុះដំណាំអីចឹងមានប្រជាជនមួយចំនួនដូចជាការអត់ឃ្លានគាត់ទៅធ្វើការនៅប្រទេសផ្សេងឬមួយយ៉ាងម៉េច?

សីង: ធ្វើការស៊ីឈ្នួលខ្មែរផងធ្វើការឲ្យថៃផង ខ្លះគេចំណាក់ស្រុកទៅឆ្ងាយអីទៅ ។

វណ្ណៈ: បាទ ។

សីង: អ្នកអត់ការងារធ្វើទេអ្នកអត់គ្នាបានធ្វើបន្តិចបន្តួចបេះតែបានហូបបន្តទៅវាមិនដាច់ពោះ ។

វណ្ណៈ: ចឹងមកដល់សព្វថ្ងៃនេះ មីងគិតឃើញថាអ្នកដែលមកពីក្នុងណាស់គេមករស់នៅទីនេះច្រើនឬក៏មិនសូវមានប៉ុន្មានទេភ្នំព្រឹកយើងនេះ?

សីង: មកនៅនេះច្រើនដែលតើ មកច្រើន ។

វណ្ណៈ: បាទ ។

សីង: មករកស៊ីផងមកស្នាក់នៅផង ។

វណ្ណៈ: ចឹងមកដល់សព្វថ្ងៃនេះតើជីវភាពរស់នៅរបស់ប្រជាជនអីហ្នឹងមិនសូវមានការលំបាកអីទេ?

សីង: បើអ្នកគ្នាអត់លំបាកហ្នឹងឯង ។

វណ្ណៈ: បាទ ។

សីង: នរណាគេមានគេជួរធារទៅ អ្នកណាអត់នៅតែអត់ចឹងគ្នាទើបមកទិញដីចឹងស្នាក់នៅចឹង ។

វណ្ណៈ: បាទ ។

សីង: គ្នាអត់ទៅ គេអ្នកនៅចាស់កម្រអ្នកអត់ណាស់ ។

វណ្ណៈ: បាទ ។

សីង: តែវាមិនមានអីបរបូរគ្រាន់តែម៉ាទប់ម៉ាទល់កូនស៊ីឈ្នួលគេទៅ ។

វណ្ណៈ: បាទ! ចឹងខ្ញុំដូចជាអស់អីសំនួរសួរមីងទៀតហើយមីងមានអីចង់និយាយបន្ថែមទៀតទេ?

សីង: អត់មានអីទេខ្ញុំ ។

វណ្ណៈ: ចឹងខ្ញុំអរគុណមីងច្រើនហើយមីងណាស់ ។

សីង: ចាស ។

**ចប់**